# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ១២២ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកំណត់តំបន់ប្រើប្រាស់ដោយចីរភាព លើផ្ទៃដីទំហំ ១៦៨,៨០ហិកតា (មួយរយហុកសិបប្រាំបីហិកតានិងប៉ែតសិបអា) ក្នុងឧទ្យានជាតិបូទុមសាគរ ស្ថិតនៅភូមិថ្មសនិងភូមិចម្លងគោ ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង និងការធ្វើអនុបយោគប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់តំបន់គ្រប់គ្រងលើផ្ទៃដីទំហំ ១៦៨,៨០ហិកតា (មួយរយហុកសិបប្រាំបីហិកតានិងប៉ែតសិបអា) ក្នុងឧទ្យានជាតិបុទុមសាគរ ស្ថិតនៅភូមិថ្មសនិងភូមិចម្លងគោ ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ដូចមានផែនទីនិងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធ សម្រាប់ផ្តល់ឱ្យក្រុមហ៊ុន **រ៉ូយ៉ាល់ គ្រុប ខូ អិលធីឌី** ដើម្បីបន្តរៀបចំបំពេញបែបបទនីតិវិធីជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២ .-**

ត្រូវបានធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនូវដីទំហំ ១៦៨,៨០ហិកតា (មួយរយហុកសិបប្រាំបីហិកតានិងប៉ែតសិបអា) ដូចមានក្នុងមាត្រា១ នៃអនុក្រឹត្យនេះ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ក្រោមលក្ខខណ្ឌជួលឱ្យក្រុមហ៊ុន **រ៉ូយ៉ាល់ គ្រុប ខូ អិលធីឌី** សម្រាប់គម្រោងអភិវឌ្ឍន៍រោងចក្រអគ្គិសនីដុតធ្យូងថ្ម អានុភាព ៧០០មេហ្គាវ៉ាត់ ដែលត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថានជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋនិងក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ សីហា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


ផែនទី ស្តីពីការកំណត់តំបន់ប្រើប្រាស់ដោយចីរភាព លើផ្ទៃដីទំហំ ១៦៩,៨០ហិកតា (មួយរយហុកសិបប្រាំបួនហិកតា និងប៉ែតសិបអា) ក្នុងឧទ្យានជាតិបុទុមសាគរ
ស្ថិតនៅភូមិថ្មស និងភូមិចង្អូងគោ ឃុំថ្មស ស្រុកបុទុមសាគរ ខេត្តកោះកុង និងការធ្វើអនុបយោគប្ដូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ:..១២២.....អនក្រ.បក ចុះថ្ងៃទី...៦......ខែ..សីហា.....ឆ្នាំ២០២០
ចំណុចនិយាមកាតោលទីតាំងគម្រោង
| Id | X | Y |
|---|---|---|
| 1 | 323532 | 1204251 |
| 2 | 323341 | 1202936 |
| 3 | 323407 | 1202727 |
| 4 | 323353 | 1202701 |
| 5 | 323287 | 1202746 |
| 6 | 323273 | 1202821 |
| 7 | 323239 | 1202928 |
| 8 | 323424 | 1204192 |
| 9 | 323321 | 1204135 |
| 10 | 323061 | 1204585 |
| 11 | 322829 | 1205222 |
| 12 | 322974 | 1205260 |
| 13 | 324082 | 1205236 |
| 14 | 324378 | 1205181 |
| 15 | 324643 | 1205183 |
| 16 | 324926 | 1204964 |
| 17 | 325029 | 1204704 |
| 18 | 324819 | 1204604 |
| 19 | 324763 | 1204590 |
| 20 | 324437 | 1204543 |
| 21 | 324232 | 1204509 |
| 22 | 324099 | 1204473 |
| 23 | 323928 | 1204421 |
| 24 | 323732 | 1204360 |
ទំហំ ១៦៩,៨០ ហិកតា
ថ្មស
ចង្អូងគោ
ឧទ្យានជាតិបុទុមសាគរ
សញ្ញាសំគាល់
ទីតាំងភូមិ
ចំណុចនិយាមកា
ផ្លូវ
ខ្សែរយៈកំពស់
ស្ទឹង ឬព្រែក
ព្រំប្រទល់ទីតាំងគម្រោង
ព្រំប្រទល់ឧទ្យានជាតិបុទុមសាគរ
ទីតាំងគម្រោងអភិវឌ្ឍឯកជនក្រុមគ្រួសារ ទំហំសរុប ១៦៩.៨០ ហិកតា
0 0.25 0.5 1
km
Map Information:
Units: Meters
System: UTM, Zone 48 N
Datum: WGS 1984
322000 323000 324000 325000 326000
1203000 1204000 1205000